SET OF NUMBERED MULTILINGUAL SCHOOL NOTICES
KHMER (or CAMBODIAN)

LIST OF NOTICES IN ENGLISH

| | |
|---|---|
| Notice No 1 | **Information regarding parent participation** |
| Notice No 2 | **Participation in Parent/Teacher interview** |
| Notice No 3 | **Special Event/ Meeting/Function** |
| Notice No 4 | **Prep intake** |
| Notice No 5 | **Student Excursion Consent Form (for excursions not requiring school council approval)** |
| Notice No 6 | **End of term** |
| Notice No 7 | **No school** |
| Notice No 8 | **Collection of EMA** |
| Notice No 9 | **Travel card** |
| Notice No 10 | **Transition** |
| Notice No 11 | **Exit from English Language School or Centre** |
| Notice No 12 | **Medical-condition** |
| Notice No 13 | **Immunisation records** |
| Notice No 14 | **Fees and levies** |
| Notice No 15 | **Student absence** |
| Notice No 16 | **Swimming Program** |
| Notice No 17 | **Meeting Request** |
| Notice No 18 | **List of items required for an excursion** |

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

មានវិធីច្រើនយ៉ាងដែលលោកអ្នកអាចចូលរួមនៅក្នុងសកម្មភាពនៃសាលារៀនរបស់កូនលោកអ្នក។ សាលារៀននឹងផ្ដល់ជូនព័ត៌មានអំពីវិធីទាំងឡាយដែលលោកអ្នកអាចជួយនិងចូលរួមក្នុងការសិក្សាអប់រំរបស់កូនលោកអ្នក។ លោកអ្នកក៏អាចទទួលការអញ្ជើញទៅចូលរួមនៅក្នុងបណ្ដាសកម្មភាពនៃកម្មវិធីទាំងពួងរបស់សាលារៀនផងដែរ។

នៅក្នុងឆ្នាំនេះ សាលារៀននឹងអញ្ជើញលោកអ្នកឲ្យចូលរួមតាមរយៈការទៅចូលរួមក្នុងការប្រជុំ ព្រឹត្តិការណ៍ ឬពិធីផ្សេងៗទៀតដែលរៀបចំដោយសាលារៀន។ ការប្រជុំខ្លះនឹងប្រព្រឹត្តទៅដើម្បីផ្ដល់ព័ត៌មានអំពីកម្មវិធីសិក្សាដែលបង្រៀន ហើយការប្រជុំឯទៀតនឹងធ្វើទៅដើម្បីពិភាក្សាអំពីការរីកចម្រើនរបស់កូនលោកអ្នក។

លោកអ្នកក៏អាចចូលរួមក្នុងសកម្មភាពសាលារៀនតាមរយៈការជ្រើសរើសចូលក្នុងក្រុមប្រឹក្សាសាលារៀន ការធ្វើជាសមាជិកនៃគណៈកម្មាធិការណាមួយ ឬការជួយរៀបចំសកម្មភាពទូទៅរបស់សាលារៀន។

**បើលោកអ្នកចង់បានព័ត៌មានណាមួយអំពីក្លឹបមាតាបិតា ឬក្រុមប្រឹក្សាសាលារៀន សូមទាក់ទងសាលារៀន។**

សូមទាក់ទងគ្រូបង្រៀនរបស់កូនលោកអ្នក នាយកសាលា ឬបុគ្គលិកឯទៀតរបស់សាលារៀន បើលោកអ្នកមានបំណងពិភាក្សាបញ្ហាណាមួយដែលទាក់ទងនឹងកូនលោកអ្នកឬសាលារៀន។

ហត្ថលេខា ...........................

ថ្ងៃទី ..............................

(School letterhead/logo)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

នៅថ្ងៃទី ..........................................................................................., យើងខ្ញុំសូមអញ្ជើញលោកអ្នកទៅកាន់សាលារៀន និងជួបជាមួយ

(date/ ថ្ងៃទី)

..........................................................................................................(name of teacher/s/ ឈ្មោះគ្រូបង្រៀន)

ដើម្បីពិភាក្សាអំពីការរីកចម្រើនរបស់កូនលោកអ្នក និងកម្មវិធីនានារបស់សាលារៀន។ ការប្រជុំនេះត្រូវបានហៅថា ការពិភាក្សារវាងមាតាឬបិតានិងគ្រូបង្រៀន។ ការប្រជុំនេះផ្តល់នូវឱកាសសម្រាប់ឲ្យលោកអ្នកពិភាក្សាបញ្ហាទាំងឡាយ ផ្តល់ព័ត៌មានឬសួរសំណួរអំពីការសិក្សារបស់កូនលោកអ្នក។ ដោយសារតែការសិក្សាអប់រំតម្រូវឲ្យមានកិច្ចសហការរវាងមាតាបិតា គ្រូបង្រៀន និងសិស្ស ដូច្នេះចំណាប់អារម្មណ៍និងការចូលរួមរបស់លោកអ្នកនៅក្នុងការប្រជុំនេះគឺជាការសំខាន់។

យើងខ្ញុំទន្ទឹងរង់ចាំការជួបប្រជុំជាមួយលោកអ្នក។

ហត្ថលេខា ..................................................

ថ្ងៃទី ......................................................

------------------------------------------ ------------------------------------------X

សូមសរសេរបំពេញ កាត់ផ្តាច់ចេញ និងប្រគល់មកវិញនូវផ្នែកនៃក្រដាសនេះ កុំឲ្យហួសពីថ្ងៃទី.......................................................................

(date/ ថ្ងៃទី)

ឈ្មោះមាតាឬបិតា ឬអាណាព្យាបាល៖ ..........................................................................

ឈ្មោះសិស្ស៖ ........................................................................ ថ្នាក់ទី៖ ..................................................

សូមប្រាប់នូវពេលម៉ោងសមរម្យបំផុតសម្រាប់ការជួបពិភាក្សា តាមរយៈការគូសខ្វែងនៅក្នុងកូនប្រអប់សមស្រប។

☐............................................................ ☐..................................................

☐............................................................ ☐..................................................

☐............................................................ ☐..................................................

☐............................................................ ☐..................................................

ត្រូវការអ្នកបកប្រែភាសា ជាភាសា ......................................................................................

(language/ ភាសា)

ហត្ថលេខា ...............................................................................................................................

(Parent/Guardian/ មាតាឬបិតា ឬអាណាព្យាបាល)

ថ្ងៃទី.......................................................

(School letterhead/logo)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

យើងខ្ញុំសូមអញ្ជើញលោកអ្នកទៅចូលរួមក្នុងព្រឹត្តិការណ៍មួយរបស់សាលារៀន។ ព្រឹត្តិការណ៍នេះនឹងជាឱកាសដ៏ល្អមួយសម្រាប់ឲ្យលោកអ្នកដឹងកាន់តែច្រើនឡើងអំពីសាលារៀន និងដើម្បីជួបគ្រូបង្រៀននិងមាតាបិតាឯទៀត។

❐ការផ្តល់ព័ត៌មាននៅពេលល្ងាចសម្រាប់មាតាបិតាឬអាណាព្យាបាល អំពី ____________________

❐ការប្រជុំផ្តល់ព័ត៌មាន ដើម្បីពិភាក្សាអំពីដំណើរសិក្សាបោះជំរំរបស់សាលារៀន ____________________

❐ពិធីបញ្ចប់ត្រីមាស / ឆ្នាំសិក្សា

❐ពិធីប្រកួតកីឡាហែលទឹក / កីឡារបស់សាលារៀន

❐ការជួបជុំទទួលទានភេសជ្ជៈតែកាហ្វេនៅពេលព្រឹកសម្រាប់មាតាបិតាឬអាណាព្យាបាល

❐ព្រឹត្តិការណ៍ពិសេសសម្រាប់ ____________________

❐ផ្សេងៗទៀត ____________________

ព្រឹត្តិការណ៍នេះនឹងប្រព្រឹត្តទៅនៅឯ ____________________

នៅថ្ងៃទី ____________________វេលាម៉ោង ____________________។

❐នឹងមានអ្នកបកប្រែភាសា ❐នឹងគ្មានអ្នកបកប្រែភាសាទេ

យើងខ្ញុំសង្ឃឹមថា លោកអ្នកអាចអញ្ជើញចូលរួមបាន ហើយយើងខ្ញុំទន្ទឹងរង់ចាំក្នុងការជួបលោកអ្នក។

ហត្ថលេខា ………………………………..

ថ្ងៃទី …………………………………..

---

សូមសរសេរបំពេញ កាត់ផ្តាច់ចេញ និងប្រគល់មកវិញនូវផ្នែកនៃក្រដាសនេះ កុំឲ្យហួសពីថ្ងៃទី …………… (Date/ថ្ងៃទី)

ខ្ញុំ …………………… នឹង / នឹងមិន អាចចូលរួម។ កូនខ្ញុំឈ្មោះ ……………………….

ខ្ញុំនឹងត្រូវការអ្នកបកប្រែភាសា **បើសិនជាមាន** ❐

ត្រូវការអ្នកបកប្រែភាសា ជាភាសា……………………………….

ហត្ថលេខា…………………………………………… ថ្ងៃទី…………………………………………….

(School letterhead/logo)

(Date/ថ្ងៃទី)

មាតាបិតាឬអាណាព្យាបាល

យើងខ្ញុំមានការរីករាយថា ............................................ (student's name/ឈ្មោះសិស្ស) នឹងចូលសិក្សានៅសាលារៀនយើងខ្ញុំនៅឆ្នាំក្រោយនេះ។ យើងខ្ញុំសូមអញ្ជើញលោកអ្នកទៅកាន់សាលារៀននៅមុនពេលឆ្នាំសិក្សាចាប់ផ្តើម ដើម្បីជួបនិងពិភាក្សាជាមួយគ្រូបង្រៀនរបស់កូនលោកអ្នក។ យើងខ្ញុំនឹងរីករាយក្នុងការពិភាក្សាជាមួយលោកអ្នកនូវរាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងកូនលោកអ្នកនិងសកម្មភាពរបស់សាលារៀន ព្រមទាំងវិធីទាំងឡាយដែលលោកអ្នកនិងបុគ្គលិកសាលារៀនអាចធ្វើការរួមគ្នា ដើម្បីធានាឲ្យមានការចាប់ផ្តើមចូលសាលារៀនដែលប្រកបដោយជោគជ័យនិងការរីករាយ សម្រាប់កូនលោកអ្នក។

ជាការប្រសើរ បើលោកអ្នកអាចអញ្ជើញទៅដល់សាលារៀននៅម៉ោង ..................................(time/ម៉ោង)

នៅថ្ងៃទី................................................(Date/ថ្ងៃទី)

សូមយកកូនលោកអ្នកមកជាមួយលោកអ្នក។ យើងខ្ញុំទទួលស្វាគមន៍សមាជិកឯទៀតនៃគ្រួសារលោកអ្នក។

ជាការប្រសើរ បើលោកអ្នកអាចអញ្ជើញទៅដល់សាលារៀននៅម៉ោង ..................................(time/ម៉ោង)

នៅថ្ងៃទី................................................(Date/ថ្ងៃទី)

សូមយកកូនលោកអ្នកមកជាមួយលោកអ្នក។ យើងខ្ញុំទទួលស្វាគមន៍កុមារឯទៀត។

ហត្ថលេខា....................................................

ថ្ងៃទី ............................................................

-------------------------------------------------- --------------------------------------------------

សូមសរសេរបំពេញ កាត់ផ្តាច់ចេញ និងប្រគល់មកវិញនូវផ្នែកនៃក្រដាសនេះ កុំឲ្យហួសពីថ្ងៃទី ............................

(Date/ថ្ងៃទី)

ឈ្មោះមាតាឬបិតា ឬអាណាព្យាបាល៖ ...............................................................

ឈ្មោះសិស្ស៖ ...................................................................................................

☐ អាច

ខ្ញុំ ទៅសាលារៀននៅថ្ងៃទី.........................................................ម៉ោង.........................

(Date/ថ្ងៃទី) (Time/ ម៉ោង)

☐ មិនអាច

ត្រូវការអ្នកបកប្រែភាសា ជាភាសា៖ ...............................................................

(Language/ភាសា)

ហត្ថលេខា .........................................................................................................................................

(Parent/Guardian/មាតាឬបិតា ឬអាណាព្យាបាល)

ថ្ងៃទី .......................................

(School letterhead/logo)

(Date/ថ្ងៃទី)

**ក្រដាសផ្ដល់ការអនុញ្ញាតសម្រាប់ដំណើរសិក្សានៅក្រៅសាលារៀនរបស់សិស្ស**

**(សម្រាប់ដំណើរសិក្សានៅក្រៅសាលារៀនដែលមិនចាំបាច់មានការយល់ព្រមពីក្រុមប្រឹក្សាសាលារៀន)** **KHMER 5**

**ចំណងជើងនៃដំណើរសិក្សានៅក្រៅសាលារៀន៖**

---

**គោលដៅនៃដំណើរសិក្សានៅក្រៅសាលារៀន៖**

---

**ថ្ងៃខែឆ្នាំនៃដំណើរសិក្សានៅក្រៅសាលារៀន៖**

---

**ម៉ោងចេញដំណើរនិងវិលមកវិញ៖**

**សិស្សនឹងធ្វើដំណើរតាម៖** ☐រថយន្តក្រុង ☐រថភ្លើង ☐ ត្រែម(tram) ☐ដើរ

**បុគ្គលិកនិងការមើលខុសត្រូវ៖**

**ថ្លៃ៖**

**អាហារថ្ងៃត្រង់៖**

☐ កូនលោកអ្នកគួរយកទៅជាមួយនូវអាហារថ្ងៃត្រង់និងភេសជ្ជៈដាក់ក្នុងប្រអប់ដែលមិនអាចបែកបាក់។

☐ អាចទិញអាហារថ្ងៃត្រង់ក្នុងអំឡុងដំណើរសិក្សានៅក្រៅសាលារៀនក្នុងតម្លៃ $.....

☐ ថ្លៃសម្រាប់អាហារថ្ងៃត្រង់រួមបញ្ចូលនៅក្នុងថ្លៃនៃដំណើរសិក្សានៅក្រៅសាលារៀនហើយ។

**សំលៀកបំពាក់និងសម្ភារៈដែលត្រូវការ៖**

**ឈ្មោះនៃអ្នកសម្រាប់ទាក់ទងនៅគ្រាត្រូវការជំនួយសង្គ្រោះបន្ទាន់ នៅពេលធ្វើដំណើរសិក្សានៅក្រៅសាលារៀន និងព័ត៌មានសម្រាប់ទាក់ទង៖**

**ឯទៀត៖**

**បើលោកអ្នកមានសំណួរឬការបារម្ភណាមួយ សូមទាក់ទង ........................................................**

**តាមទូរសព្ទលេខ ..........................** (phone number/លេខទូរសព្ទ)។

**ការអនុញ្ញាតរបស់មាតាឬបិតា៖**

ខ្ញុំផ្ដល់ការអនុញ្ញាតឱ្យកូនខ្ញុំ (full name/ឈ្មោះពេញ)

---

---

ចូលរួម។

---

---

មាតាឬបិតា ឬអាណាព្យាបាល (full name/ឈ្មោះពេញ)

---

---

(signature/ហត្ថលេខា)

---

(Date/ថ្ងៃទី)

---

In case of emergency I can be contacted on:
នៅគ្រាត្រូវការជំនួយសង្គ្រោះបន្ទាន់  គេអាចទាក់ទងខ្ញុំតាមទូរសព្ទលេខ៖

________________________________ OR/ឬ:
Phone/ ទូរសព្ទ

________________________________
Phone/ ទូរសព្ទ

**ការអនុញ្ញាតឱ្យទទួលការព្យាបាល**

នៅពេលដែលគ្រូបង្រៀនទទួលខុសត្រូវដំណើរសិក្សាមិនអាចទាក់ទងខ្ញុំបាន  ឬមិនអាចអនុវត្តបានក្នុងការទាក់ទងខ្ញុំ    ខ្ញុំអនុញ្ញាតឱ្យគ្រូបង្រៀនដែលទទួលខុសត្រូវ៖

- អនុញ្ញាតឱ្យកូនខ្ញុំទទួលការព្យាបាលឬវះកាត់  ដែលវេជ្ជបណ្ឌិតព្យាបាលចាត់ទុកថាជាការចាំបាច់
- អនុវត្តជំនួយសង្គ្រោះដំបូង  នៅគ្រាដែលគ្រូបង្រៀនទទួលខុសត្រូវចាត់ទុកថាជាការចាំបាច់សមហេតុផល។

ហត្ថលេខារបស់មាតាឬបិតា  ឬអាណាព្យាបាល៖
___

___

ថ្ងៃទី៖
___

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

សាលារៀនបញ្ចប់នៅថ្ងៃ ..............................................................................................................................

(day/ថ្ងៃនៃសប្តាហ៍) (date/ថ្ងៃទី)

វេលាម៉ោង.................................សម្រាប់ត្រីមាស/វិស្សមកាលដំណាច់ឆ្នាំសិក្សា។

(time/ម៉ោង)

សាលារៀននឹងចាប់ផ្តើមឡើងវិញនៅថ្ងៃ ..................................................................................................ម៉ោង.................ព្រឹក។

(day/ ថ្ងៃនៃសប្តាហ៍) (date/ ថ្ងៃទី) (time/ម៉ោង)

ហត្ថលេខា ...............................................

ថ្ងៃទី ..................................................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

សាលារៀននឹងបិទទ្វារមិនដំណើរការនៅថ្ងៃ..................................................................................................................

(day/ ថ្ងៃនៃសប្ដាហ៍) (date/ថ្ងៃទី)

សូមកុំបញ្ជូនកូនលោកអ្នកទៅសាលារៀននៅនឹងថ្ងៃនោះឡើយ។

មូលហេតុ៖

- ថ្ងៃសិស្សឈប់ (ថ្ងៃសម្រាប់គ្រូបង្រៀនធ្វើកម្មវិធីសិក្សា) ☐
- ថ្ងៃឈប់សម្រាកសាធារណៈ ☐
- ផ្សេងៗទៀត ☐

ហត្ថលេខា ..........................................

ថ្ងៃទី ............................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

សែកប្រាក់លើកទីមួយ / ទីពីរ នៃប្រាក់ជំនួយសិក្សាអប់រំបានមកដល់សាលារៀនហើយ។ យើងខ្ញុំសុំឱ្យលោកអ្នកអញ្ជើញមកកាន់ការិយាល័យសាលារៀនដោយផ្ទាល់ខ្លួនដើម្បីចុះហត្ថលេខាទទួលយកសែកនេះ។ សូមកាន់យកលិខិតនេះមកជាមួយលោកអ្នក។

ហត្ថលេខា.....................................................

ថ្ងៃទី.........................................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

ប័ណ្ណសម្បទានធ្វើដំណើរអាចឲ្យសិស្សធ្វើដំណើរតាមយានជំនិះសាធារណៈ ដោយបង់ថ្លៃថោកជាងធម្មតា។

សិស្សដែលចុះឈ្មោះសិក្សានៅសាលារៀន មានសិទ្ធិទទួលប័ណ្ណសម្បទាន។ ដើម្បីដាក់ពាក្យសុំប័ណ្ណសម្បទានធ្វើដំណើររបស់សិស្ស មាតាបិតាត្រូវបំពេញពាក្យសុំ ដែលមាននៅឯសាលារៀន ឬនៅតាមស្ថានីយរថភ្លើង ហើយភ្ជាប់ជាមួយនូវរូបថតពណ៌នៃកូនលោកអ្នកពីរសន្លឹកដែលមានទំហំប៉ុនរូបថតសម្រាប់លិខិតឆ្លងដែន។ ពាក្យសុំនិងរូបថតទាំងនេះត្រូវបោះត្រាដោយសាលារៀន និងដាក់នៅឯស្ថានីយរថភ្លើង។

**សិស្សអាចប្រើប័ណ្ណសម្បទានរៀងរាល់ថ្ងៃ។ យ៉ាងណាមិញសូមកត់សម្គាល់ថា ច្បាប់តម្រូវឲ្យអ្នកធ្វើដំណើរត្រូវតែមានប័ណ្ណសម្បទានសម្រាប់សិស្សធ្វើដំណើរតាមយានជំនិះរដ្ឋវិកតូរីយ៉ា (VPT) ដែលមានសុពលភាពត្រឹមត្រូវ នៅពេលធ្វើដំណើរតាមរយៈការបង់ថ្លៃសំបុត្រដែលចុះថ្លៃ រាល់ពេលដែលជិះយានជំនិះសាធារណៈទាំងអស់។ ការផាកពិន័យអាចនឹងអនុវត្ត បើមិនអាចបង្ហាញប័ណ្ណសម្បទានធ្វើដំណើររបស់សិស្សដែលមានសុពលភាព នៅពេលមានសំណូមពរឲ្យបង្ហាញទេនោះ។**

បើសិស្សណាមួយបាត់ប័ណ្ណរបស់ខ្លួន សិស្សនោះត្រូវបង់ប្រាក់ចំនួន $ ........... សម្រាប់ថ្លៃចេញប័ណ្ណថ្មីមួយទៀត។

ហត្ថលេខា ......................................................

ថ្ងៃទី ......................................................

**បើលោកអ្នកចង់បានព័ត៌មានបន្ថែម ឬមានសំណួរណាមួយអំពីសេវាយានជំនិះសាធារណៈ METLINK ផ្តល់ជូនលេខទូរសព្ទមួយដែលមានអ្នកបកប្រែភាសា។**

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

ខ្ញុំបានទទួលព័ត៌មានថា  កូនលោកអ្នក..........................................................................................................

(Name/ឈ្មោះ)

នឹងចូលរៀននៅថ្នាក់ទី 7 នៅឆ្នាំក្រោយ  នៅ៖

(School/សាលារៀន)..........................................................................................

(Address/អាសយដ្ឋាន) ..........................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

ទូរសព្ទ៖ ..........................................................................................................

លោកអ្នកអាចទាក់ទង ..........................................................................................តាមទូរសព្ទលេខ..............................

(name of contact person and position/ឈ្មោះអ្នកទាក់ទង និងមុខតំណែង) (phone/ទូរសព្ទ)

បើលោកអ្នកមានបំណងពិភាក្សាបញ្ហាណាមួយថែមទៀតអំពីសាលារៀន  ដូចជាការចុះឈ្មោះនិងឯកសណ្ឋានជាដើម។

ហត្ថលេខា ........................................................

ថ្ងៃទី ..........................................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

កូនលោកអ្នក ........................................................................................ បានបំពេញសព្វគ្រប់នូវវគ្គភាសាអង់គ្លេស

(Name/ឈ្មោះ)

របស់ខ្លួន ហើយត្រៀមជាស្រេចដើម្បីចូលសិក្សានៅតាមសាលារៀនទូទៅ។ កូនលោកអ្នកនឹងសិក្សានៅ៖

សាលារៀន៖ អាសយដ្ឋាន៖ ........................................................................................

........................................................................................

អ្នកទាក់ទង៖ ........................................................................................

ទូរសព្ទ៖ ........................................................................................

បើលោកអ្នកមានសំណួរណាមួយ លោកអ្នកអាចទាក់ទងសាលាឬមណ្ឌលបង្រៀនភាសា៖

........................................................................................ តាមទូរសព្ទលេខ ....................................................

(Contact person/អ្នកទាក់ទង) (Phone/ទូរសព្ទ)

ហត្ថលេខា ........................................................

ថ្ងៃទី ........................................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

លោកអ្នកត្រូវប្រាប់សាលារៀន បើកូនលោកអ្នកមានស្ថានភាពជំងឺយូរពេល (ឧទាហរណ៍៖ ហឺត ស្កន់ ប្រតិកម្មទំនាស់ ទឹកនោមផ្អែម ខាន់លឿង ឈាមមិនកក ឬរោគបេះដូង) ដែលអាចប៉ះពាល់ខ្លួនគេនៅពេលនៅសាលារៀន។ ព័ត៌មានទាំងអស់នឹងត្រូវលាក់ការសម្ងាត់។

ថ្នាំពេទ្យទាំងអស់ដែលប្រើនៅសាលារៀន ត្រូវដាក់ឈ្មោះរបស់កូនលោកអ្នក កម្រិតប្រើ និងពេលត្រូវប្រើ។

ថ្នាំពេទ្យទាំងអស់ត្រូវប្រគល់ទៅឲ្យគ្រូបង្រៀន លើកលែងតែលោកអ្នកបានធ្វើការរៀបចំឯទៀតជាមួយនឹងគ្រូបង្រៀន (ឧទាហរណ៍៖ ជាធម្មតា សិស្សត្រូវទុកថ្នាំហឺតដោយខ្លួនឯង)។

ថ្នាំបំបាត់ការឈឺចាប់អាចផ្តល់ឲ្យដោយមានការអនុញ្ញាតពីមាតាបិតាឬអាណាព្យាបាលតែប៉ុណ្ណោះ។

បើលោកអ្នកមានបំណងពិភាក្សាស្ថានភាពជំងឺរបស់កូនលោកអ្នក សូមទូរសព្ទទៅ ................................................................................ ...............

(name/ឈ្មោះ)

តាមលេខ .................................. ដើម្បីធ្វើការណាត់ជួប។

(phone/ទូរសព្ទ)

ហត្ថលេខា...........................................................

ថ្ងៃទី ........................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

សិស្សត្រូវបង្ហាញសលាកប័ត្រថ្នាំបង្ការរោគនៅពេលចុះឈ្មោះជាលើកដំបូងនៅតាមសាលាបឋមសិក្សាក្នុងរដ្ឋវិកតូរីយ៉ា។

**សលាកប័ត្រនេះបញ្ជាក់ថាតើសិស្សនេះបានទទួលថ្នាំបង្ការរោគខាន់ស្លាក់ តេតាណូស ស្លាប់ដៃជើង កញ្ជ្រឹល សាឡាទែន ស្អូច ក្អកមាន់ និងគ្រុនខាន់លឿងប្រភេទ B ។**

សិស្សដែលផ្ទេរសាលារៀនក៏ត្រូវបង្ហាញសលាកប័ត្រថ្នាំបង្ការរោគផងដែរ។

សិស្សអាចទទួលថ្នាំបង្ការរោគតាមរយៈសាលាក្រុង មណ្ឌលសុខភាពមាតានិងទារក ហើយនិងវេជ្ជបណ្ឌិតក្នុងតំបន់។

**សិស្សដែលមិនទទួលថ្នាំបង្ការរោគនៅតែអាចចូលរៀនបាន។ បើការរាលដាលនៃជំងឺឆ្លងកើតមានឡើងនៅសាលារៀន សិស្សទាំងនោះនឹងត្រូវបញ្ជូនឲ្យទៅផ្ទះ រហូតទាល់តែគ្រោះថ្នាក់លែងកើតមានតទៅទៀត។**

បើកូនលោកអ្នកបានទទួលថ្នាំបង្ការរោគ សូមធ្វើឲ្យប្រាកដថា លោកអ្នកយកសលាកប័ត្រថ្នាំបង្ការរោគទៅជាមួយលោកអ្នក នៅពេលអញ្ជើញទៅសាលារៀនដើម្បីចុះឈ្មោះកូនលោកអ្នក។

ហត្ថលេខា......................................................

ថ្ងៃទី.........................................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

សាលារៀនទទួលប្រាក់ពីក្រសួងសិក្សាអប់រំនិងការរីកចម្រើននៃកុមារវ័យក្មេងដើម្បីផ្តល់កម្មវិធីសាលារៀន ប៉ុន្តែមានការរំពឹងថា មាតាបិតានឹងផ្តល់ឬបង់ឲ្យសាលារៀននូវថ្លៃសៀវភៅសិក្សា ប្រដាប់ប្រដារសរសេរ ដំណើរសិក្សានៅក្រៅសាលារៀន ដំណើរសិក្សាបោះជំរំនិងសកម្មភាពវប្បធម៌ទាំងឡាយ ព្រមទាំងសម្ភារៈនៃកម្មវិធីសិក្សាមានតម្លៃថ្លៃសម្រាប់មុខវិជ្ជាអនុវត្តន៍ខ្លះ នៅពេលដែលសិស្សយកទៅផ្ទះនូវវត្ថុដែលធ្វើរួចហើយ។

សម្រាប់ឆ្នាំនេះ សាលារៀននឹងសុំឲ្យមាតាបិតាបង់ប្រាក់ចំនួន $........................ សម្រាប់សកម្មភាពនិងវត្ថុទាំងនេះ។

បន្ថែមពីលើសកម្មភាពនិងវត្ថុខាងលើនេះ ជាធម្មតាក្រុមប្រឹក្សាសាលារៀនសុំឲ្យមាតាបិតាផ្តល់វិភាគទានស្ម័គ្រចិត្តដើម្បីជួយដល់ការរៃអង្គាសប្រាក់របស់សាលារៀន។

សម្រាប់ឆ្នាំនេះ សាលារៀនសុំឲ្យមាតាបិតាផ្តល់អំណោយចំនួន $................. ប្រាក់នេះគឺជាការស្ម័គ្រចិត្ត។

សាលារៀនអាចផ្តល់ឱវាទអំពីជំនួយប្រាក់កាសដែលមានសម្រាប់មាតាបិតា។ សូមទាក់ទងសាលារៀន បើលោកអ្នកមានបំណងពិភាក្សាជម្រើសផ្សេងទៀតដើម្បីបង់ប្រាក់។

ហត្ថលេខា ......................................

ថ្ងៃទី.......................................................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

យើងខ្ញុំមានការបារម្ភថា ……………………………….… (student's name/ឈ្មោះសិស្ស) នៅថ្នាក់ទី ………..

មិនបានទៅសាលារៀននៅថ្ងៃ ………………………………………………..…………………………..

(day/s and date/s / ថ្ងៃនៃសប្ដាហ៍ និងថ្ងៃទី)

និង …………………………………………………….....................…

(day/s and date/s / ថ្ងៃនៃសប្ដាហ៍ និងថ្ងៃទី)

សូមសរសេរប្រាប់នូវមូលហេតុដែលកូនលោកអ្នកមិនបានទៅសាលារៀន នៅក្នុងផ្នែកប្រគល់មកវិញនៅខាងក្រោមនេះ ហើយផ្ញើទៅសាលារៀនវិញឲ្យបានរហ័សតាមលទ្ធភាព។

បើកូនលោកអ្នកមិនបានទៅសាលារៀនដោយគ្មានការអនុញ្ញាតពីលោកអ្នកទេ លោកអ្នកអាចទាក់ទងសាលារៀនដើម្បីពិភាក្សាបញ្ហានេះតទៅទៀត។

ហត្ថលេខា ………………………………………… ថ្ងៃទី …………………………………………

---

សូមសរសេរបំពេញ កាត់ផ្ដាច់ចេញ និងប្រគល់មកវិញនូវផ្នែកនៃក្រដាសនេះ ឲ្យបានរហ័សតាមលទ្ធភាព។

កូនខ្ញុំ ……………………………………………………………………………… មិនបានទៅសាលារៀននៅថ្ងៃ

(student's name/ឈ្មោះសិស្ស)

……………………………………………………………………………………………………………………

(day/s and date/s / ថ្ងៃនៃសប្ដាហ៍ និងថ្ងៃទី)

ដោយសារតែមូលហេតុដូចតទៅនេះ៖

❐ មានជំងឺ ❐ មានការណាត់ជួបជាមួយវេជ្ជបណ្ឌិត ❐ មានការណាត់ជួបជាមួយពេទ្យធ្មេញ

❐ មានធុរៈក្នុងគ្រួសារ ❐ មិនទៅសាលារៀន**ដោយគ្មាន**ការអនុញ្ញាតពីខ្ញុំ

❐ មានមូលហេតុផ្សេងទៀត (ផ្ដល់សេចក្ដីពិស្ដារ) ………………………………………………………………………

ហត្ថលេខា…………………………………………… ថ្ងៃទី ……………………………………………

(Parent/Guardian/មាតាឬបិតា ឬអាណាព្យាបាល)

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់មាតាបិតាឬអាណាព្យាបាល

កម្មវិធីហែលទឹករបស់សាលារៀននឹងប្រព្រឹត្តទៅនៅឯ (ទីកន្លែង) ........................................................................................... ....

.....................................................................................(address/អាសយដ្ឋាន)

នៅថ្ងៃទី ...............................................................................................រវាងម៉ោង ...................................................

(dates/ថ្ងៃទី) (times/ពេលម៉ោង)

កម្មវិធីហែលទឹករបស់សាលារៀនគឺសម្រាប់សិស្សទាំងអស់។

សិស្សទាំងឡាយត្រូវបានអមដំណើរនិងមើលខុសត្រូវដោយគ្រូបង្រៀនរបស់ខ្លួន ហើយត្រូវបានបង្ហាត់ជាក្រុមតូចៗ ដោយគ្រូបង្ហាត់ហែលទឹកដែលមានការហ្វឹកហ្វឺន។

សូមប្រាប់គ្រូបង្រៀនរបស់កូនលោកអ្នកអំពីកាលៈទេសៈណាមួយដែលសាលារៀនគួរដឹង ដូចជាស្ថានភាពជំងឺជាដើម។

នៅពេលហែលទឹកនីមួយៗ សិស្សនឹងត្រូវយកទៅជាមួយនូវវត្ថុដូចតទៅនេះ៖

☐ ខោអាវហែលទឹក

☐ កន្សែងពោះគោ

☐ មួកហែលទឹក (បើចង់ពាក់)

☐ វ៉ែនតាពាក់ពេលហែលទឹក (បើចង់ពាក់)

☐ ខោអាវរលុង ដូចជាខោអាវប្រភេទ tracksuit ជាដើម

កម្មវិធីហែលទឹកនេះនឹងអស់ថ្លៃ $ ...................................................... នៅគ្រានីមួយៗ។ (ថ្លៃសរុប $ ................................. )

............................................................................ហត្ថលេខា

-------------------------------------------- -----------------------------------------------------

សូមសរសេរបំពេញ កាត់ផ្តាច់ចេញ និងប្រគល់មកវិញនូវផ្នែកនៃក្រដាសនេះ កុំឲ្យហួសពីថ្ងៃទី ...............

(date/ថ្ងៃទី)

ខ្ញុំផ្តល់ / មិនផ្តល់ ការអនុញ្ញាតទៅឲ្យ________________________________, ថ្នាក់ទី៖ ............... ,

(student's name/trx here)

ដើម្បីចូលរួមក្នុងកម្មវិធីហែលទឹករបស់សាលារៀន។

☐ ខ្ញុំមានបំណងបង់ប្រាក់ $ សម្រាប់ពេលហែលទឹកនីមួយៗ។

ឬ

☐ ខ្ញុំមានបំណងបង់ប្រាក់សម្រាប់កម្មវិធីហែលទឹកទាំងមូល។ ភ្ជាប់ជាមួយនូវប្រាក់ចំនួន $

សូមទាក់ទងសាលារៀន បើលោកអ្នកមានបំណងពិភាក្សានូវជម្រើសផ្សេងទៀតដើម្បីបង់ប្រាក់។

ហត្ថលេខា .............................................................................

(Parent/Guardian / មាតាឬបិតាឬអាណាព្យាបាល)

ថ្ងៃទី ...........................

(School letterhead/logo)

(Date/ថ្ងៃទី)

ជម្រាបមកដល់ ..................................................,

ខ្ញុំមានបំណងអញ្ជើញលោកអ្នកទៅចូលរួម៖

❐ការប្រជុំមួយដើម្បីពិភាក្សាអំពីរបាយការណ៍សិក្សារបស់កូនលោកអ្នក

❐ការប្រជុំមួយដើម្បីពិភាក្សាអំពីការរីកចម្រើនរបសកូនលោកអ្នក

❐ការប្រជុំមួយដើម្បីពិភាក្សាអំពីការមិនទៅសាលារៀនរបស់កូនលោកអ្នក

សូមអញ្ជើញមកកាន់សាលារៀននៅថ្ងៃទី ______________________ វេលាម៉ោង ________________

ដើម្បីជួប ______________________________________________________________។

នឹងមានអ្នកបកប្រែភាសា បើលោកអ្នកត្រូវការសម្រាប់ការប្រជុំនេះ។

យើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងអាចចូលរួមបាន។ សូមទាក់ទងសាលារៀនតាមទូរសព្ទលេខ ................ បើលោកអ្នកមិនអាចជួបបាននៅពេលវេលាដែលបានរៀបចំនេះ ហើយមានបំណងរៀបចំពេលប្រជុំ ផ្សេងមួយទៀត។

ហត្ថលេខា ...................................

ថ្ងៃទី .......................................

---

សូមសរសេរបំពេញ កាត់ផ្តាច់ចេញ និងប្រគល់មកវិញនូវផ្នែកនៃក្រដាសនេះ កុំឲ្យហួសថ្ងៃទី ............

(Date/ថ្ងៃទី)

ខ្ញុំ ....................... នឹង / នឹងមិន អាចចូលរួមបានទេ។ កូនខ្ញុំឈ្មោះ ...........................

ខ្ញុំនឹងត្រូវការអ្នកបកប្រែភាសា **បើមាន** ❐ មិនត្រូវការអ្នកបកប្រែភាសាទេ ❐

ត្រូវការអ្នកបកប្រែភាសា ជាភាសា ....................................

ហត្ថលេខា ..................................................

ថ្ងៃទី.........................................

សិស្សទាំងឡាយគួរយកទៅជាមួយនូវវត្ថុនានាដែលគូស ✓ នៅខាងក្រោម សម្រាប់ដំណើរសិក្សាបោះជំរំ។
ត្រូវសរសេរឈ្មោះសិស្សនៅលើវត្ថុទាំងអស់។

## 1. សម្រាប់ដំណេក

☐ ភួយ ☐ ពូកដំណេកក្នុងស្បោង (sleeping bag) ☐ ស្បែកជើងផ្ទាត់ពាក់ក្នុងផ្ទះ

☐ ខ្នើយកើយតូច ☐ ខោអាវដំណេក ☐ ពូកសប់ខ្យល់

☐ កន្ទេលដំណេក

## 2. សម្រាប់ពាក់នៅពេលថ្ងៃ

☐ ខោខូវប៊យ / ខោជើងវែង ☐ មួកការពារពន្លឺថ្ងៃ ☐ មួកធ្វើឲ្យកក់ក្តៅ

☐ ខោខ្លី ☐ កន្សែងបង់ក ☐ មួកការពារភ្លៀង

☐ អាវសឺមី ☐ ស្រោមជើង ☐ ស្រោមដៃ

☐ ខោអាវទ្រនាប់សម្រាប់ផ្លាស់ ☐ អាវស៊ុកធ្វើឲ្យកក់ក្តៅ ☐ អាវខ្សៀនស៊ុកធ្វើឲ្យកក់ក្តៅ

☐ អាវកក់ក្តៅដៃវែង ឬអាវរងា ☐ ខោអាវទ្រនាប់រងា

☐ អាវមិនជ្រាបទឹកឬអាវភ្លៀង ☐ ស្បែកជើងសម្រាប់រត់ ☐ ស្បែកជើងកៅស៊ូកវែង

☐ ស្បែកជើងសម្រាប់ដើរ ☐ ស្បែកជើងសង្រែក ☐ ស្បែកជើងផ្ទាត់

☐ ខោអាវហែលទឹក

## 3. វត្ថុផ្ទាល់ខ្លួន

☐ កន្សែងពោះគោ ☐ ក្រែមការពារពន្លឺថ្ងៃ ☐ ក្រាសសិតសក់

☐ ប្រេងលាបកុំឲ្យសត្វល្អិតខាំ ☐ ក្រដាសជូតមាត់ឬកន្សែងដៃ

☐ សាប៊ូកក់សក់ ☐ សាប៊ូ ☐ ដបដាក់ទឹកបរិភោគ

☐ គ្រឿងបរិក្ខារពេទ្យសម្រាប់តម្រូវការផ្ទាល់ខ្លួន

## 4. សម្រាប់ការបរិភោគ

☐ ចានទាប ☐ ចានសម្ល ☐ ពែង

☐ កាំបិត / សម / ស្លាបព្រា ☐ កន្សែងជូតចាន

## 5. ផ្សេងៗទៀត

☐ សៀវភៅលំហាត់ / សៀវភៅសរសេរ ☐ ប៊ិចនិងខ្មៅដៃ ☐ ម៉ាស៊ីនថតរូប

☐ ស្បោងផ្លាស្ទិកសម្រាប់ដាក់ខោអាវត្រូវបោក ☐ ពិលនិងថ្មពិល

☐ ស្រោមសំបុត្រដែលមានអាសយដ្ឋាននិងតែមរួចជាស្រេច

## 6. **លុយសម្រាប់ចាយ៖** ចំនួនមិនលើសពី $.........